**វិធានការការពារ**



- ត្រូវរុំ(ខ្ចប់)ជាបន្ទាន់ (ដោយប្រើថង់ប្លាស្ទិច ឬក្រដាស)នៅពេលក្ដិបម្រះចាប់ផ្ដើមស្រពោន។
- ត្រូវបេះផ្លែដែលខូចៗចេញហើយយកទៅកប់ចោលក្នុងដី ឬដុតចោល(ដើម្បីសម្លាប់ដង្កូវរុយក្នុងផ្លែខូច)។
- ប្រើនុយអន្ទាក់ ហ្វេរ៉េមូនញី សរាប់ទាក់ទាញរុយឈ្មោលនៅជុំវិញចំការ។នៅពេលរុយឈ្មោលចូលក្នុអន្ទាក់ហើយយើងត្រូវប្រមូលវាចេញពីអន្ទាក់ឲ្យបាន ញឹកញាប់។
- យើងអាចប្រើដបទឹកសុទ្ធ ឬកំប៉ុងជ័រ ចោះរន្ធប៉ុនម្រាមដៃចំនួនពីរ នៅផ្នែកខាងលើ។
- ចោះខ្សែលួសសំរាប់ដាក់នុយអន្ទាក់ ហ្វេរ៉េមូនញី ក្នុងកំប៉ុង
- ដាក់កំប៉ុងចំនួនប៣ ទៅ៤ ក្នុងផ្ទៃដីចំនួន៥០០ម២
- ត្រូវផ្លាស់ប្ដូរនុយរវាងពី៥ទៅ៧ថ្ងៃម្ដង។

ខ-ចៃ

ត្រូវពិនិត្យមើលចៃអោយបានញឹកញាប់ នៅផ្នែកខាងក្រោមស្លឹក។ចៃជាភ្នាក់ ងារចំលងជម្ងឺវីរុស ដែលបណ្ដាលអោយស្លឹក និងគ្រួយម្រះរួញ។

**វិធានការកំចាត់**

- កាត់ស្លឹកដែលមានចៃយកទៅកប់ ដុតចោល ឬញេចដោយដៃ
- ប្រើថ្នាំពុលកសិកម្ម
  -អាបាមិចទីន(Abamectin)
  -ឌីណូតីហ្វូរ៉ង់(Dinotefuran)
  -ហ្វីប្រូនីល(Fipronil)

**សំគាល់:**

- មិនត្រូវយកថ្នាំពុលកសិកម្មលាយចូលគ្នាច្រើនមុខសំរាប់បាញ់ទេ (ថ្នាំអាចមានប្រតិកម្មជាមួយគ្នា ធ្វើអោយមិនមានប្រសិទ្ធភាព)។
- ត្រូវជ្រើសរើសយកក្បាលបាញ់ទុយយោបាញ់ ដែលមានលក្ខណសាចល្អ ទើបថ្នាំនៅជាប់និងដើម ស្លឹក បន្លែ
- ត្រូវប្រើទឹកស្អិតលាយជាមួយថ្នាំនៅពេលបាញ់ថ្នាំ

➢ ជម្ងឺ